# កិច្ចតែងការបង្រៀន

- មុខវិជ្ជា៖ ភាសាខ្មែរ
- ប្រធានបទ៖ ការស្គាល់តួអក្សរ
- ខ្លឹមសារ ៖ សមត្ថភាពគូសនិងសរសេរតួអក្សរ
- សកម្មភាពគោល៖ ល្បែង
- ចំណងជើងមេរៀន ៖ «គូសតាមស្នាមចុចពាក្យមាន់និងផាត់រូបភាពមាន់»
- ថ្នាក់កម្រិត ខ្ពស់
- រយៈពេល ៣០នាទី

## ១.វត្ថុបំណង

- វិជ្ជាសម្បទា៖ កុមារប្រាប់បានពីរបៀបគូសភ្ជាប់តួអក្សរទៅនឹងរូបភាពបានត្រឹមត្រូវតាមរយៈការបំផុសសំណួរនិងការណែនាំរបស់គ្រូ។
- បំណិនសម្បទា៖ កុមារកំណត់បានពីរបៀបគូសភ្ជាប់តួអក្សរទៅនឹងរូបភាពបានត្រឹមត្រូវតាមរយៈការអនុវត្តផ្ទាល់។
- ចរិយាសម្បទា៖មានបញ្ញាស្មារតី អត់ធ្មត់ តស៊ូព្យាយាមក្នុងការអនុវត្តកិច្ចការ។

## ២.សម្ភារៈឧបទេស

- សម្ភារៈគ្រូ៖ ខ្មៅដៃ សន្លឹកកិច្ចការ គូល័រ
- សម្ភារៈសិស្ស៖  ខ្មៅដៃ សន្លឹកកិច្ចការ គូល័រ
- ការរៀបចំ ៖ អង្គុយរាងអក្សរអ៊ុយ

## ៣.ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -តើក្រុមរបស់កូនមកជុំគ្នាហើយរឺនៅ?<br>- កូនណាមានកាន់របស់យកទៅទុកហើយពិនិត្យមើលដៃបើប្រលាក់ទៅលាងដៃឲ្យស្អាតនិងមើលតើកៅអីកូនអង្គុយត្រង់ជួរហើយរឺនៅ?<br>-កូនក្រោកឈរច្រៀងបទ (ល្បែងកាយវិការ) | ជំហានទី១<br>លំនឹងថ្នាក់<br>– ពង្រឹងសណ្តាប់ធ្នាប់<br>– អនាម័យនិងវិន័យ<br>- ប្រមូលអារម្មណ៍ | –បាទ/ចាស់មកជុំហើយ<br>- អនុវត្តតាមការណែនាំ<br>- ធ្វើតាមគ្រូ |

| | | |
|---|---|---|
| | ជំហានទី២<br>រំឭកមេរៀនចាស់ | |
| -តើកាលពីថ្ងៃមុនអ្នកគ្រូបានបង្រៀនភាសាខ្មែរពីអ្វីដែរកូន? | -ការស្គាល់តួអក្សរះ អក្សរម | -ឆ្លើយ |
| -តើអក្សរមានពាក្យនិងរូបភាពអ្វីខ្លះ | -មាន់ ម្ជូក មូស | -ឆ្លើយរៀបរាប់ |
| -នៅផ្ទះកូនមានចិញ្ចឹមសត្វអ្វីខ្លះ? | +ទំនាក់ទំនងមេរៀនថ្មី –<br>មាន់ ឆ្កែ ឆ្មា .... | -ឆ្លើយរៀបរាប់ |
| | ជំហានទី៣<br>មេរៀនថ្មីះ គូសតាមចុចពាក្យមាន់និងផាត់ពណ៌រូបមាន់ | |
| -ចឹងថ្ងៃនេះអ្នកគ្រូមានមេរៀនថ្មីមកបង្រៀនកូនៗ | -ល្បែងះគូសតាមចុចពាក្យមាន់និងផាត់ពណ៌រូបមាន់ | -ស្តាប់ |
| -នាំកុមារអានចំណងជើងមេរៀន | -អានចំណងជើងមេរៀន | -អានតាមគ្រូ |
| -បង្ហាញសម្ភារៈរួចឱ្យកុមាររៀបរាប់ | -សម្ភារៈគូល័រ សន្លឹកកិច្ចការ<br><br> | -មើលនិងរៀបរាប់ |
| -ណែនាំកុមារពីរបៀបគូសតាមស្នាមចុចនិងផាត់ពណ៌ឱ្យបានត្រឹមត្រូវ | -ណែនាំពីរបៀបគូស | -ស្តាប់ |
| -ចែកសម្ភារៈដល់កុមារ | -ចែកសម្ភារៈ | -ទទួលនិងអនុវត្ត |
| – គ្រូដើរសម្របសម្រួល | -សម្របសម្រួល | -ស្តាប់តាមការណែនាំ |
| -ផ្ទៀងផ្ទាត់លទ្ធផល | -ផ្ទៀងផ្ទាត់លទ្ធផល | -ស្តាប់ដោយយកចិត្តទុកដាក់ |

| | | |
|---|---|---|
| -តើអំបាញ់មិញអ្នកគ្រូបង្រៀនកូនអំពីអ្វី? | ជំហានទី៤<br>ពង្រឹងចំណេះដឹង<br>-ល្បែង៖គូសតាមចុចពាក្យមាន់និងផាត់ពណ៌រូបមាន់ | ឆ្លើយ |
| -ថ្ងៃនេះអ្នកគ្រូសប្បាយចិត្តខ្លាំងណាស់ដែលកូនៗយកចិត្តទុកដាក់ចូលរួមលេងល្បែងជាមួយមិត្តភក្តិនិងអ្នកគ្រូ | ជំហានទី៥<br>បណ្តាំផ្ញើ<br>- លើកសរសើរ | -ស្តាប់ដោយសប្បាយរីករាយ |
| -ដូចនេះពេលត្រលប់ទៅផ្ទះកូនជម្រាបប៉ាម៉ាក់កូនលេងល្បែងគូសតាមចុចពាក្យមាន់និងផាត់ពណ៌រូបមាន់ | - ផ្តាំផ្ញើ | - បាទ/ចាស |

ថ្ងៃចន្ទ៦រោចខែជេស្ឋ ឆ្នាំម្សាញ់ឆស័កព.ស២៥៦៩
ត្រូវនឹងថ្ងៃទី១៦ខែមិថុនា ឆ្នាំ២០២៥
គ្រូបន្ទុកថ្នាក់

មាន សុផា

បានឃើញនិងឯកភាព
នាយិកាសាលា

អ៊ុខ_ណារឿន